**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៧៣. សសរ**

# សេចក្ដីសម្រេច

# ស្ដីពី

# ការបង្កើតគណៈកម្មការរៀបចំការប្រកួតកីឡាតំបន់ឆ្នេរ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតគណៈកម្មការរៀបចំការប្រកួតកីឡាតំបន់ឆ្នេរ ខេត្តព្រះសីហនុ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១២ និងជារៀងរាល់ឆ្នាំបន្តបន្ទាប់ មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្ដម | **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍<br>និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | **ប្រធាន** |
| ២- ឯកឧត្ដម | **ប៊ុន សុខ** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា . អនុប្រធានទី២ គ.ជ.អ.ក<br>និងជាប្រធានសហព័ន្ធខ្មែរកីឡាអត្តពលកម្មស្ម័គ្រចិត្ត | **អនុប្រធាន** |
| ៣- ឯកឧត្ដម | **ស្បោង សារ៉ាត់** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | **អនុប្រធាន** |
| ៤- ឯកឧត្ដម | **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | **អនុប្រធាន** |
| ៥- ឯកឧត្ដម | **ស៊ីន សុខន** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ | **អនុប្រធាន** |
| ៦- លោក | **វ៉ាត់ ចំរើន** | អគ្គលេខាធិការគ.ជ.អ.ក | **អនុប្រធានអចិន្ត្រៃយ៍** |
| ៧- ឯកឧត្ដម | **ឡាយ ឫទ្ធី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ | **សមាជិក** |

| | | | |
|---|---|---|---|
| ៨- | ឯ.ឧត្តមសេនីយ៍ត្រី **ពាក់ វណ្ណថា** | ស្នងការនគបាលខេត្តព្រះសីហនុ | **សមាជិក** |
| ៩- | ឯ.ឧត្តមសេនីយ៍ត្រី **ហ៊ាង ធីន** | មេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះសីហនុ | **សមាជិក** |
| ១០- | លោក HIDETOSHI OCHIAI | នាយកក្រុមហ៊ុន CEO Co., Ltd. | **សមាជិក** |
| ១១- | លោក **សែម ផល្លា** | នាយករងក្រុមហ៊ុន CEO Co., Ltd. | **សមាជិក** |
| ១២- | លោក **ជិន សារិន** | អភិបាលនៃគណៈអភិបាលក្រុងព្រះសីហនុ | **សមាជិក** |
| ១៣- | លោក **ភ៉ន់ ឈួន** | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ | **សមាជិក** |
| ១៤- | លោក **ជា ប៊ុនអៀង** | ប្រធានការិយាល័យកីឡានៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ | **សមាជិក** |
| ១៥- | លោក **សេង ខា** | ប្រធានស្តីទីមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ | **សមាជិក** |
| ១៦- | លោក **ភ៉ត់ ស្រ៊ុន** | តំណាង គ.ជ.អ.ក ប្រចាំខេត្តព្រះសីហនុ | **សមាជិក** |

**ប្រការ២:** គណៈកម្មការរៀបចំការប្រកួតកីឡាតំបន់ឆ្នេរ ខេត្តព្រះសីហនុមានមុខងារ និងភារកិច្ចដូចតទៅ ៖

- រៀបចំកម្មវិធី និងការផ្សព្វផ្សាយ
- រៀបចំបដិសណ្ឋារកិច្ចស្វាគមន៍ ការធ្វើដំណើរ ហូបចុកស្នាក់នៅ
- ជួយសម្រួលបែបបទធ្វើដំណើរ បែបបទគយជូនដល់គណៈប្រតិភូកីឡា តាមច្រកទ្វារព្រំដែនអន្តរជាតិ ទាំងពេលធ្វើដំណើរ មកដល់ និងត្រឡប់វិញ។

**ប្រការ៣:** គណៈកម្មការនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅគណៈកម្មាធិការជាតិអូឡាំពិក មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក **ភ៉ត់ ចំរើន** | អគ្គលេខាធិការ គ.ជ.អ.ក | **ប្រធាន** |
| ២- | លោក **សែម ផល្លា** | នាយករងក្រុមហ៊ុន CEO Co., Ltd. | **អនុប្រធាន** |
| ៣- | លោក **ប៉ែន វុទ្ធី** | អគ្គលេខាធិការសហព័ន្ធកីឡាអត្តពលកម្មស្ម័គ្រចិត្ត | **អនុប្រធាន** |
| ៤- | លោក **ហែម សំណាង** | អគ្គលេខាធិការរង គ.ជ.អ.ក | **សមាជិក** |
| ៥- | លោក **ហែម ថុន** | ប្រធាននាយកដ្ឋាន.រដ្ឋបាល គ.ជ.អ.ក | **សមាជិក** |
| ៦- | លោក **ណយ ផាណា** | ប្រធាននាយកដ្ឋាន.ទំ/ទំ និងសហប្រតិបត្តិការអន្តរជាតិ គ.ជ.អ.ក | **សមាជិក** |
| ៧- | លោក **កាំង សុធា** | ប្រធាននាយកដ្ឋាន.ទីផ្សា និងផ្សព្វផ្សាយ គ.ជ.អ.ក | **សមាជិក** |
| ៨- | លោក **តុប បញ្ញា** | ប្រធានគណនេយ្យ គ.ជ.អ.ក | **សមាជិក** |
| ៩- | លោក **ឈួន ឡេង** | អនុប្រធាននាយកដ្ឋាន.រដ្ឋបាល គ.ជ.អ.ក | **សមាជិក** |
| ១០- | លោក **ម៉ុយ ឡាត** | ប្រធានប្រព័ន្ធ IT កីឡា | **សមាជិក** |

**ប្រការ៤:** លេខាធិការដ្ឋាននេះមានមុខងារ និងភារកិច្ចដូចតទៅ៖

- សំរបសំរួលការងារប្រជុំ និងព្រឹត្តិការណ៍ប្រកួត។

- ធ្វើការរៀបចំស្ប៊តផ្សព្វផ្សាយតាមបណ្ដាញព័ត៌មានក្នុងប្រទេស និងក្រៅប្រទេស ជាពិសេសតាមវិទ្យុ ទូរទស្សន៍ ដើម្បីឱ្យសាធារណជនបានយល់ជ្រួតជ្រាប និងចូលរួមក្នុងព្រឹត្តិការណ៍ប្រកួត ។
- ជ្រើសរើសកីឡាករ-កាវិនីកម្ពុជា ដើម្បីចូលរួមប្រកួតជាមួយកីឡាករបរទេស ។
- រៀបចំ និងជួយសម្រួលបែបបទនៃការធ្វើដំណើរ និងបែបបទគយនៅតាមច្រកទ្វារព្រំដែនអន្តរជាតិនានា កន្លែងស្នាក់នៅ ហូបចុកជូនគណៈប្រតិភូ និងកីឡាករ-កាវិនីអន្តរជាតិ
- រៀបចំពិធីបើក-បិទតាមដំណាក់កាលប្រកួត និងពិធីជប់លៀងផ្សេងៗ ។
- ធ្វើរបាយការណ៍បូកសរុបអំពីលទ្ធផលនៃការរៀបចំ និងកិច្ចដំណើរការនៃការប្រកួតកីឡាតំបន់ឆ្នេរ ជូនថ្នាក់ដឹកនាំ និងប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៥:** - គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិកាបន្ថែមរបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាក្នុងករណីចាំបាច់ ។

- គណៈកម្មការនេះមានសិទ្ធិជ្រើសរើសកន្លែងប្រើប្រាស់មន្ត្រីពាក់ព័ន្ធក្រោមឱវាទក្នុងករណីចាំបាច់ ។

**ប្រការ៦:** - សមាជិកនៃគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

- គណៈកម្មការនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច ។

**ប្រការ៧:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អគ្គស្នងការនគរបាលជាតិ អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ព្រមទាំងសាមីខ្លួនដែលមានចែងក្នុង**ប្រការ១** និង**ប្រការ៣** ត្រូវអនុវត្ត សេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១២**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ